# មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (អង្គការសេដាក)

## ១. ប្រវត្តិរបស់អង្គការសេដាក

មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា(សេដាក) គឺជាអង្គការកសិកម្មនិងអភិវឌ្ឍន៍ជនបទដែលបានបង្កើតឡើង នៅខែសីហា ឆ្នាំ១៩៩៧ ដោយមានការគាំទ្រដំបូងពីអង្គការបារាំង មានឈ្មោះថា ហ្គ្រេត (GRET)។ មជ្ឈមណ្ឌលនេះត្រូវបានបង្កើតឡើងដើម្បីធ្វើការងារអភិវឌ្ឍន៍ផ្នែកកសិកម្មជាលក្ខណៈគ្រួសារតាមគោលការណ៍ធម្មជាតិ និងដើម្បីជម្រុញចលនាសហការ និងការជួយគ្នាទៅវិញទៅមក នៅតាមតំបន់ជនបទនៃប្រទេសកម្ពុជា។

## ២. ចក្ខុវិស័យរបស់សេដាក

សេដាក ធ្វើការដើម្បីកសាងសង្គមកម្ពុជាមួយ ដែលគ្រួសារកសិករមានជីវភាពធូរធារមានការសហការគ្នាទៅវិញទៅមក មានសិទ្ធិ និងអំណាចក្នុងការកំណត់ជោគវាសនា ដោយខ្លួនឯង ព្រមទាំងដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្គត់ផ្គង់ស្បៀងអាហារប្រកបដោយសុវត្ថិភាពដល់សង្គមទាំងមូល។

## ៣. លទ្ធផលនិងការងារកន្លងមក

- កសិករប្រមាណ ១០០.០០០នាក់ នៅភូមិចំនួន ៣.២០០ ក្នុងខេត្តចំនួន ២០ បានបង្កើនកំរិតជីវភាពតាមរយៈការសហការជាមួយ សេដាក
- យុវជនប្រមាណ ៤០០នាក់ ដែលក្នុងនោះយុវជនជនជាតិដើមភាគតិច ៤០នាក់ ទទួលបានការបណ្តុះបណ្តាលពីសេដាក
- អ្នកពាក់ព័ន្ធ និងអ្នកមានអាជីពជាអ្នកអភិវឌ្ឍន៍ចំនួនជាង ៥.០០០ នាក់ទទួលបានការបណ្តុះបណ្តាល សិក្ខាសាលា ទស្សនកិច្ចសិក្សា និងសកម្មភាពផ្សេងៗ
- ទស្សនាវដ្ដីកសិករចំនួន ១៣២ លេខ ត្រូវបានបោះពុម្ពផ្សព្វផ្សាយទូទាំងប្រទេស
- បានណែនាំប្រព័ន្ធប្រពលវប្បកម្មស្រូវ (ប.វ.ស) តាំងពីឆ្នាំ ២០០០ ហើយបច្ចុប្បន្ន (ប.វ.ស) ត្រូវបានផ្សព្វផ្សាយយ៉ាងទូលាយទូទាំងប្រទេស ដោយរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល
- គាំទ្របង្កើតឲ្យមានសមាគមកសិករជាង ១.០០០ និងផ្សាភ្ជាប់ជាមួយបណ្តាញកសិករ និងធម្មជាតិ
- គាំទ្រដល់ក្រុមសន្សំប្រាក់ដើម្បីភាពអាស្រ័យដោយខ្លួនឯងចំនួនជាង ៤.០០០ ក្រុម
- បង្កើតសហគ្រាស សេដាក ដែលដើរតួនាទីសំខាន់ក្នុងការផ្សាភ្ជាប់កសិករទៅនឹងទីផ្សារ
- គាំទ្រការបង្កើតនូវសហព័ន្ធក្រុមផលិតស្រូវសរីរាង្គថ្នាក់ជាតិប្រមាណ ២៧០ក្រុម
- មានការគាំទ្រដល់ក្រុមស្ត្រីចំនួន ៥៧០ក្រុមក្នុងខេត្តចំនួន៩
- គាំទ្រដល់កសិករក្រីក្រចំនួន១.៣០០គ្រួសារឲ្យមានលទ្ធភាពបញ្ជូនកូនចំនួន ២.៥០០នាក់ ទៅរៀនបានទៀងទាត់
- គាំទ្រដល់អ្នករស់នៅជាមួយមេរោគអេដស៍ចំនួន៣០០នាក់
- ពង្រឹងសមត្ថភាពក្រុមប្រឹក្សាឃុំចំនួន ៩៣ឃុំ ដើម្បីលើកកំពស់អភិបាលកិច្ចមូលដ្ឋាន
- បង្កើត និងគាំទ្រដល់សហគមន៍កសិករប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រចំនួន ៥
- គាំទ្រដល់សមាគមសន្សំប្រាក់គ្រូបង្រៀនជនបទចំនួន ៥០សមាគម
- គាំទ្រនិងពង្រឹងសមត្ថភាពដល់សហគមន៍ព្រៃឈើចំនួន ៣
- បង្កើនសមត្ថភាពចិញ្ចឹមជីវិតដល់គ្រួសារកសិករ នៅតំបន់អភិរក្សចំនួន ៤ ។



## ៤. ផែនការយុទ្ធសាស្ត្រសំរាប់ឆ្នាំ ២០១០-២០១៤

**គោលបំណងរួម**

ពង្រឹងសមត្ថភាព និងភាពជាម្ចាស់របស់កសិករ ៥០០.០០០ គ្រួសារនៅទូទាំងប្រទេស ក្នុងការកែលម្អគុណភាពជីវិតរបស់ខ្លួន និងចូលរួមយ៉ាងសកម្ម ក្នុងការអភិវឌ្ឍន៍សង្គម។

**គោលបំណងអភិវឌ្ឍន៍សំខាន់ៗ**

- លើកស្ទួយលក្ខខណ្ឌសុខភាពជាពិសេស ចំណីអាហារូបត្ថម្ភ និងអនាម័យ
- អភិវឌ្ឍន៍សកម្មភាពរួម និងការសហការគ្នារវាងកសិករ និងអ្នកពាក់ព័ន្ធ
- បង្កើនចំណេះដឹង និងជឿជាក់លើខ្លួនឯងរបស់ប្រជាកសិករ
- បង្កើនប្រាក់ចំណូល និងប្រាក់សន្សំ
- បង្កើនគុណភាពធនធានធម្មជាតិ និងបរិស្ថាន
- បង្កើនការចូលរួមលើអភិបាលកិច្ចមូលដ្ឋាន

## ៥. ក្រុមគោលដៅ និងអ្នកទទួលផលប្រយោជន៍

<u>ក្រុមគោលដៅ និងអ្នកទទួលផលប្រយោជន៍ចំបង</u>

- គ្រួសារកសិករ ក្រុមដែលងាយរងគ្រោះ ក្រុមអ្នកផ្ទុកមេរោគអេដស៍ និងក្រុមជនជាតិភាគតិច ជាពិសេសផ្តោតលើអ្នកដែលក្រីក្របំផុត
- យុវជនជនបទពិសេសយុវជនបោះបង់សាលារៀន

<u>ក្រុមគោលដៅដទៃៗទៀត</u>

- ក្រុមគ្រូបង្រៀនតាមជនបទ
- ក្រុមប្រឹក្សាឃុំ និងស្រុក
- ក្រុមអ្នកមានអាជីពអភិវឌ្ឍន៍ ។

## ៦. ប្រធានបទ ឬវិស័យការងារសំខាន់ៗ

- បង្កើតបច្ចេកទេសថ្មីៗលើវិស័យកសិកម្មតាមគោលការណ៍ធម្មជាតិ
- បង្កើនការផ្គត់ផ្គង់ធនធាន និងសម្ភារៈកសិកម្ម
- ពង្រីកទីផ្សារ និងអភិវឌ្ឍន៍ពាណិជ្ជកម្ម

- អភិវឌ្ឍន៍សមាគមកសិករ និងជំនួញសហករណ៍
- អង្គការកសិករ និងបណ្តាញ
- បង្កើនការប្រើប្រាស់ប្រព័ន្ធស្រោចស្រព
- បង្កើតការងារនិងអាជីពដល់យុវជនជនបទជាពិសេសគឺស្ត្រី
- បង្កើនការអប់រំដល់ក្មេងៗនៃគ្រួសារក្រីក្របំផុត
- ពង្រឹងសមត្ថភាពដល់កសិករដើម្បីសំរបទៅនឹងបំរែបំរួលអាកាសធាតុ
- សហគមន៍គ្រប់គ្រងធនធានធម្មជាតិ
- លើកកំពស់ជីវភាព ដល់ក្រុមអ្នករស់នៅជាមួយមេរោគអេដស៏ និងក្រុមងាយរងគ្រោះ
- លើកកំពស់អភិបាលកិច្ចមូលដ្ឋាន
- បង្កើនការជំរុញដល់ការប្រើប្រាស់ទឹកស្អាត ។

## ៧. សកម្មភាពនិងសេវាកម្ម

**ពង្រឹងសមត្ថភាពដល់កសិករ អ្នកមានអាជីពជាអ្នកអភិវឌ្ឍន៍ និងអ្នកពាក់ពន្ធ័**

- សេវាកម្មផ្សព្វផ្សាយវិស័យកសិកម្មដែលដឹកនាំដោយកសិករ
- ការបណ្តុះបណ្តាល និងបង្រៀនដោយកសិករ
- បណ្តុះបណ្តាលជំនាញដល់យុវជនជនបទ
- ការបណ្តុះបណ្តាល និងបង្រៀនដល់អ្នកមានអាជីពជាអ្នកអភិវឌ្ឍន៍
- ការបណ្តុះបណ្តាល និងបង្រៀនដល់ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាស្រុក
- ការរៀបចំ និងសំរបសំរួលសិក្ខាសាលាស្តីពីការពង្រឹងសមត្ថភាព
- ការទទួលទស្សនកិច្ចសិក្សា និងអន្តេវសិកភាព

**ការស្រាវជ្រាវ និងបោះពុម្ពផ្សាយ**

- សកម្មភាពស្រាវជ្រាវ ដោយមានការចូលរួម និងការស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៍ជនបទ
- ការបោះពុម្ព និងផ្សព្វផ្សាយពីបទពិសោធន៍កសិកម្ម និងអភិវឌ្ឍន៍ជនបទ
- ការរៀបចំឲ្យមានវេទិកាសន្ទនាមតិលើគោលនយោបាយអភិវឌ្ឍន៍
- ការសំរបសំរួលដល់បណ្តាញអ្នកធ្វើការលើវិស័យអភិវឌ្ឍន៍

**ការអភិវឌ្ឍន៍ស្ថាប័ន និងការគាំទ្រលើការគ្រប់គ្រងស្ថាប័ន**

- អង្គការអ្នកផលិត និងសហករណ៍ទីផ្សារ
- សហគមន៍សន្សំ និងសហករណ៍ឥណទាន
- សហគមន៍កសិករអ្នកប្រើប្រាស់ទឹក
- សមាគមអ្នកដាំកៅស៊ូជាលក្ខណ:គ្រួសារ
- សហគមន៍ និងបណ្តាញអង្គការតាមមូលដ្ឋាន
- សមាគមអ្នកផ្តល់សេវាកម្មកសិកម្ម និងអភិវឌ្ឍន៍ជនបទ

## ៨. ផ្នែកផ្សេងៗរបស់សេដាក

- **កម្មវិធីអភិវឌ្ឍន៍មូលដ្ឋាន:** ជាផ្នែកដែលគ្រប់គ្រងនិងប្រតិបត្តិគំរោងរបស់ សេដាក រយ:ពេលវែង
- **វិទ្យាស្ថានអភិវឌ្ឍន៍មូលដ្ឋានសេដាក:** បណ្តុះបណ្តាលអាជីពដល់យុវជនជនបទ និងបណ្តុះបណ្តាលអ្នកមានអាជីពអភិវឌ្ឍន៍ និងផ្តល់សេវាកម្មបណ្តុះបណ្តាលរយ:ពេលខ្លី
- **សេវាកម្មស្រាវជ្រាវដើម្បីការអភិវឌ្ឍន៍សេដាក:** ការស្រាវជ្រាវដើម្បីអភិវឌ្ឍន៍ សិក្សាពីលទ្ធភាពបង្កើតគំរោង និងវាយតំលៃគំរោង
- **បោះពុម្ពផ្សាយនិងទំនាក់ទំនង:** បោះពុម្ព និងផ្សព្វផ្សាយគ្រប់ឯកសាររបស់ សេដាក
- **កម្មវិធីសុខភាពនិងបរិស្ថាន:** បង្កើនការយល់ដឹងដល់កសិករលើការប្រើប្រាស់ថ្នាំពុលនិងបញ្ហារបស់វា, ការអប់រំ និងការបញ្ជាក់ពីគុណភាពផលិតផលធម្មជាតិ
- **កម្មវិធីគាំទ្រជំនួញសហគមន៍:** គាំទ្រទីផ្សារដល់អ្នកផលិតនិងជួយដល់ការលក់រួមទិញរួម
- **ហិរញ្ញវត្ថុ និងរដ្ឋបាលទូទៅ:** គណនេយ្យនិងហិរញ្ញវត្ថុ ការគ្រប់គ្រងធនធានមនុស្ស និងការិយាល័យ ។

## ៩. រចនាសម្ព័ន្ធអង្គការ និងអភិបាល

- សមាជ (General Assembly: GA) (ជាសមាជិកបុគ្គលិក និងអ្នកមិនមែនជាបុគ្គលិក)
- ក្រុមប្រឹក្សាភិបាល សេដាក (Board of Directors: BOD) (មានសមាជិកចំនួន ៧ រូប ដែលធ្វើការបោះឆ្នោតជារៀងរាល់បីឆ្នាំម្តងដោយសមាជ)
- គណ:កម្មាធិការដឹកនាំ សេដាក (CEDAC Steering Committee: CSC) (មានសមាជិកចំនួន ៩ រូប ដែលធ្វើការបោះឆ្នោតជារៀងរាល់ពីរឆ្នាំម្តងដោយសមាជ)
- គណ:កម្មការប្រតិបត្តិ សេដាក (CEC: CEDAC Executive Committee)
- ក្រុមសម្របសម្រួល សេដាក (CEDAC Coordinating Team: CCT)

## ១០. ទំនាក់ទំនង


- **ទីស្នាក់ការកណ្តាលសេដាក:** ផ្ទះលេខ១១៩ ផ្លូវលេខ ២៥៧ សង្កាត់ទឹកល្អក់ ១ ខណ្ឌទួលគោក ប្រអប់សំបុត្រ ១១១៨ ភ្នំពេញ
- **ទូរស័ព្ទ:** ៨៥៥-២៣ ៨៨០ ៩១៦
- **ទូរសារ:** ៨៥៥-២៣ ៨៨៥ ១៤៦
- **អ៊ីម៉ែល:** cedacinfo@cedac.org.kh
- **គេហទំព័រ:** www.cedac.org.kh






# Overview of CEDAC Agriculture and Rural Development Plan 2010-2014
## January 2010

### 1. About CEDAC

The Centre d'Etude et de Développement Agricole Cambodgien/Cambodian Center for Study and Development in Agriculture, or CEDAC, is an agricultural and rural development NGO that was formed in August 1997 with initial support from the French NGO, GRET. Since then, CEDAC developed as leading Cambodian NGO in the field of Agriculture and Rural development.

### 2. CEDAC Vision

CEDAC envisions a Cambodian society where small farmers enjoy good living conditions and strong mutual cooperation with the right and power to determine their own destiny while playing an important role in supplying healthy food for the whole society.

### 3. Overview of the past achievements

- More than 100,000 small farmer families (5 % of total farmer families) in 3,200 village of 20 provinces improve their socio-economic conditions by cooperating with CEDAC
- Around 400 rural youth, include 40 indigenous youth received professional training
- More than 5000 development professionals and stakeholders participated in training, workshop and exchange program of CEDAC
- 132 issues of monthly Farmer Magazine other publications, documenting farmer good practices, are widely disseminated
- System of Rice Intensification (SRI) introduced by CEDAC in 2000 spread throughout Cambodia by government and NGOs
- More than 1000 villages associations are assisted to form the independent national farmer associations network, known as Farmer and Nature Net (FNN)
- Initiated and support more than 4000 village-based saving groups (Saving for self-reliance)
- Pioneer in linking small producer to market, which lead to the formation of an independent marketing company, Sahakreas CEDAC, as a social enterprise



- 400 organic rice producer groups supported
- 570 women groups assisted
- 1300 poorest families were enabled to send 2500 children to schools regularly
- 300 PLHAs families improve their livelihood conditions
- 93 commune councils are supported in term of good/democratic governance
- 5 Farmer Water User Communities (FWUC) are supported.
- Supported the formation of 50 Rural teacher saving associations for self-reliant development
- 3 Community Forestry supported
- Improve livelihood of small farmer living in 4 protected areas

### 4. Plan for 2010-2014

**The overall objective**

To strengthen the capacity and ownership of 500,000 small farmers to improve quality of life and to participate actively society development.

**Key areas of development Indicators**

- Improved health conditions (mainly improved food, nutrition and sanitation)
- Developed collective action and mutual cooperation among farmers and stakeholders
- Improved knowledge and self-confidence
- Improved income and saving capital
- Improved quality of natural resources and environment
- Improved participation in local governance

### 5. Target groups and Beneficiaries

**Primary target groups and beneficiaries**

- Small farmers, with special focus on poorest, vulnerable groups, PLHAs and indigenous community
- Rural youth, especially school drop- outs

**Other target groups (local multiplication)**

- Rural school teachers
- Commune and district councilors
- Development professionals

### 6. Thematic focus

- Technical innovation in ecological agriculture
- Improved access to agricultural inputs and supplies
- Improving market access and developing fair trade
- Developing farmer association and cooperative business
- Community-based organization and networks
- Improving access to irrigation
- Employment and career for rural youth Rural women empowerment
- Improving education for children of poorest families

- Farmer capacity to adapt to Climate Change
- Community based natural resources management
- Livelihood improvement for PLHAs and vulnerable groups
- Improving local governance
- Improving access to clean water

## 7. Activities and Services

**Capacity building to farmers, development professionals and other stakeholders**

- Agricultural extension services (farmer led agricultural extension)
- Training and coaching of farmers
- Professional training for rural youth
- Training and coaching of development professionals
- Training and coaching of commune and district councilors
- Organize and facilitate capacity building workshop
- Hosting exchange visit and internship

**Research, exchange, dialogue and publication**

- Implementing participatory action research and development oriented research
- Publication and dissemination of good practices in agriculture and rural development
- Organize development and policy dialogue forum
- Coordinate and facilitating networking among development practitioners and stakeholders

**Organizational development and management support**

- Producer organization and marketing cooperative
- Saving and credit cooperatives
- Farmer Water User Community
- Family rubber planter associations
- Rural school teacher saving associations
- Community-based organizations and networks
- Agriculture and local development service provider association (ALDA)

## 8. CEDAC departments

- **Field Program:** Managing and implementing long-term field projects of CEDAC
- **CEDAC Institute of Local Development (CILD):** Professional training of rural youth and training of development professionals and short-term training services
- **CEDAC Research for Development (CRD):** Development oriented research, project feasibility, monitoring and evaluation studies
- **Publication and Communication:** Production and dissemination of all CEDAC publications
- **Health and Environment:** Monitoring and raising awareness on agro-chemical issues, organic standards certification and education
- **Community Business Support (CBS):** Marketing support to producers and assistance to marketing and input supply organization/cooperative
- **General Finance and Administration (GFA):** Accounting and Finance, Human Resources Management, Logistics and Procurement and Office Management

## 9. Organizational Structure and Governance

- General Assembly: Met every year, consisting of all CEDAC staff members
- CEDAC Board of Directors: Consisting of 7 members, met 3 times per year
- CEDAC Steering Committee (CSC): Consisting of nine elected members
- CEDAC Executive Committee (CEC): Representatives of all departments/units of CEDAC, met every week to review and coordinate daily activities of CEDAC
- CEDAC Coordination Team (CCT): Consisting of representatives of all departments, units and selected projects, met every month to review and coordinate all CEDAC activities

## 10. Contact Information


- **CEDAC Head Office:** Street 257, #119, Sangkat Teuk La-ak I, Khan Toul Kok Phnom Penh, P.O Box 1118
- **Tel:** 855-23 880 916
- **Fax:** 855-23 885 416
- **Email:** cedacinfo@cedac.org.kh
- **Website:** www.cedac.org.kh




